ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ

THE STUDENT MOVEMENT FOR DEMOCRACY

លេខ៖ ០០១០/២០ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

# លិខិតចំហ

## ចំពោះលោក ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** យល់ឃើញថា កិច្ចសន្ទនាតាមទូរស័ព្ទរបស់លោក **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជា ជាមួយលោក **ង្វៀន ភូ ត្រុង** អគ្គលេខាធិការមជ្ឈឹមបក្សនៃគណបក្សសង្គមនិយមវៀតណាម និងជាប្រធានរដ្ឋវៀតណាម កាលពីអំឡុងកណ្ដាលសប្ដាហ៍មុន មានតម្លៃត្រឹមតែជាអត្ថន័យនៃប្រវត្តិសាស្ត្ររត់តាមពីក្រោយមហិច្ឆតាប្រយោជន៍វៀតណាម ដើម្បីបង្កើតសមិទ្ធផលដ៏ធំធេងឲ្យវៀតណាម ពីកិច្ចសហប្រតិបត្តិការស៊ីជម្រៅ លើគ្រប់វិស័យជាមួយកម្ពុជាប៉ុណ្ណោះ។

យើងខ្ញុំកត់សម្គាល់ឃើញថា ក្រៅតែពីសាររីករាយនឹងការសន្ទនា, ការអបអរសាទរចំពោះសមិទ្ធផលនៃទំនាក់ទំនង, ការសរសើរអំពីជោគជ័យរបស់វៀតណាម, ការសម្ដែងការជឿជាក់លើវៀតណាម, និងការវាយតម្លៃខ្ពស់នៃកិច្ចសហប្រតិបត្តិការនោះ លោក **ហ៊ុន សែន** មិនបានធ្វើសំណូមពរអ្វីសោះ ទៅកាន់លោក **ង្វៀន ភូ ត្រុង** ខណៈពេលកងទ័ពវៀតណាម បន្តបោះតង់យ៉ាងតិច ៣០០តង់ នៅតាមព្រំដែន រំលោភអធិបតេយ្យភាពកម្ពុជា និងស្របពេលវៀតណាមកំពុងបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិបងប្អូនខ្មែរកម្ពុជាក្រោម។ រីឯលោក **ង្វៀន ភូ ត្រុង** ក្រៅតែពាក្យបញ្ចោរ និងការអរគុណលោក **ហ៊ុន សែន** នោះ ប្រធានរដ្ឋវៀតណាមបានជំរុញលោក **ហ៊ុន សែន** ឲ្យបន្តអនុវត្តន៍កិច្ចសន្យារវាងគ្នា ឲ្យបានល្អ និងបានលើកសំណើឲ្យលោក **ហ៊ុន សែន** ជួយមើលថែជនជាតិវៀតណាមនៅកម្ពុជា ទាំងមិននិយាយដល់ពាក្យ**«ខុសច្បាប់ ឬស្របច្បាប់»**ផង ហើយលោក **ហ៊ុន សែន** បានសន្យាបន្តសម្រួលតាមបំណងរបស់វៀតណាម។

លោក **ង្វៀន ភូ ត្រុង** បានសម្ដែងសេចក្ដីប្រាថ្នា ***«សូមឲ្យភាគីកម្ពុជា បន្តការជួយសម្រួលនិងបង្កលក្ខណៈងាយស្រួលដើម្បីបងប្អូនមានដើមកំណើតវៀតណាម អាចមានជីវភាពរស់នៅប្រកបដោយស្ថិរភាព បានរៀនសូត្រនិងប្រកបមុខរបរយូរអង្វែងនៅប្រទេសកម្ពុជា ... »*** ហើយលោក **ហ៊ុន សែន** បានអះអាងថា ***«កម្ពុជានឹងបន្តការជួយសម្រួលនិងបង្កលក្ខណៈងាយស្រួលដល់បងប្អូនមានដើមកំណើតវៀតណាម ដើម្បីបងប្អូនមានលំនឹងចិត្តបន្តការរស់នៅក្នុងប្រទេសកម្ពុជា»***។ នេះពុំមែនជាលើកទីមួយទេ ដែលពួកមេដឹកនាំវៀតណាមបានលើកសំណើបែបនេះ និងកន្លងមក រហូតដល់ធ្វើសំណូមពររបៀបបង្គាប់ឲ្យក្រុមមេដឹកនាំរដ្ឋាភិបាល និងរដ្ឋសភាកម្ពុជា មានលោក **ទៀ បាញ់**, លោក **ស ខេង**, លោក **ហេង សំរិន** ... ផ្ដល់សញ្ជាតិខ្មែរងាយៗ ដល់ជនជាតិវៀតណាមនៅកម្ពុជា ហើយក្រុមប្រមុខរដ្ឋអំណាចកម្ពុជា សុទ្ធតែស្ម័គ្រទទួលយកមកអនុវត្តន៍សម្រួលតាមសេចក្ដីប្រាថ្នារបស់វៀតណាម។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** វាយតម្លៃថា នៅចំពោះមុខលោក **ង្វៀន ភូ ត្រុង** ដែលបានដើរតួនាទីយ៉ាងស្វាហាប់ក្នុងការបម្រើប្រយោជន៍ជាតិវៀតណាមនោះ លោក **ហ៊ុន សែន** ពុំបានបំពេញកាតព្វកិច្ចស្របតាមរដ្ឋធម្មនុញ្ញ ដើម្បីការពារប្រយោជន៍ប្រជាជាតិខ្មែរទេ។ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣៣ ចែងថា ***«ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅបរទេស ត្រូវបានរដ្ឋគាំពារ»*** និងមាត្រា៣៥ ចែងថា ***«សេចក្ដីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ»***។

យើងខ្ញុំបានធ្វើសម្ភាសន៍ដោយផ្ទាល់ ជាមួយបងប្អូនខ្មែរកម្ពុជាក្រោម អំពីស្ថានភាពរស់នៅរបស់ពួកគាត់ក្រោមសម្ពាធដ៏តឹងរ៉ឹងរបស់វៀតណាម។ ពួកគាត់បានរៀបរាប់អំពីយុទ្ធនាការនៃការធ្វើទុក្ខបុកម្នេញដោយវៀតណាម តាំងពីការចាប់ខ្លួននិងបន្តចាប់ខ្លួនពលរដ្ឋខ្មែរក្រោម ដោយគ្មានមូលហេតុច្បាស់លាស់, ការបិទទំនាក់ទំនងប្រជាពលរដ្ឋខ្មែរក្រោម ជាមួយបងប្អូនសាច់ញាតិនៅក្រៅប្រទេស, ការរឹតបន្តឹងពលរដ្ឋខ្មែរក្រោមមិនឲ្យជួបជុំគ្នាលើសពី៣នាក់...។ សារពត៌មានព្រៃនគរ បានផ្សាយថា តាំងពីឆ្នាំ២០១៧មក កម្មករខ្មែរក្រោមជាង២០០នាក់នៅខេត្តវ៉ាលប្រើស (ផុងណាយជាភាសា វៀតណាម) ត្រូវស្នួនឧស្សាហកម្មវៀតណាមដេញចេញពីការងារ ដោយហេតុផលនយោបាយរើសអើងពូជសាសន៍ និងប៉ះពាល់ សណ្ដាប់ធ្នាប់សាធារណៈ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ចាត់ទុកថា កាយវិការការទូតរបស់លោក **ហ៊ុន សែន** ចំពោះមេដឹកនាំវៀតណាម គឺជាទង្វើរំលោភខ្លឹមសាររដ្ឋធម្មនុញ្ញកម្ពុជា និងមិនបម្រើប្រយោជន៍ជនជាតិខ្មែរទូទៅ ជាពិសេសពលរដ្ឋខ្មែរ នៅលើទឹកដីកម្ពុជាក្រោមសព្វថ្ងៃ ប្រសិនបើលោក **ហ៊ុន សែន** និងរដ្ឋាភិបាលរបស់លោក ព្រមទាំងរដ្ឋសភាកម្ពុជា នៅតែធ្វើព្រងើយកន្តើយចំពោះរឿងទាំងអស់នេះ ពុំព្រមលើកយកទៅនិយាយរកដំណោះស្រាយជាមួយមេដឹកនាំវៀតណាម។

យើង ក៏ចាត់ទុកករណីបន្តព្រងើយកន្តើយរបស់រដ្ឋាភិបាលលោក **ហ៊ុន សែន** និងរដ្ឋសភាកម្ពុជា ថា ជាផែនការជួយជ្រោមជ្រែងយុទ្ធសាស្ត្រឈ្លានពានរបស់វៀតណាម មកលើបូរណភាពទឹកដីកម្ពុជា, ការបន្តបង្ហូរជនជាតិវៀតណាមខុសច្បាប់ចូលកម្ពុជា ហើយលេងល្បែងបិទភ្នែក ដេញចេញតិចតួចតាមផ្លូវធំ និងឲ្យចូលវិញតាមផ្លូវតូច, និងរឿងវៀតណាមរំលោភសិទ្ធិពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅលើទឹកដីប្រវត្តិសាស្ត្រដូនតាខ្មែរ ក្រោមការត្រួតត្រាដោយវៀតណាមសព្វថ្ងៃ។

**ប្រធានប្រតិបត្តិ**

**ឌុច ឌិបុល**

2402 24TH ST SE, WASHINGTON, DC 20020 | TEL: (202) 430-5503 | EMAIL: INFO@SMD2.NET | WWW.SMD2.NET